**សំរេច**

**ប្រការ ១ :** ត្រូវបានបង្កើតគណៈកម្មការវេចខ្ចប់ និងដឹកជញ្ជូនសំណល់ប្លាស្ទិចចំនួន ២៥០ តោន ចេញពីព្រះរាជាណាចក្រកម្ពុជា ដែលមានសមាសភាព :

១- ឯកឧត្តម ឆាន់ សាផាន់ រដ្ឋលេខាធិការក្រសួងបរិស្ថាន ប្រធាន
២- លោក ឃេង សុខុម អនុប្រធាននាយកដ្ឋានកាកពុលត្រួល អនុប្រធាន
៣- លោក ឡូយ ឫទ្ធី នាយករង ទីចាត់ការគយ និងរដ្ឋាករ សមាជិក
៤- លោក លូ គឹមឈុន ប្រធានកំពង់ផែអន្តរជាតិក្រុងព្រះសីហនុ សមាជិក
៥- លោក គាំង លាងខណ្ឌ អនុប្រធាននាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក ។

**ប្រការ ២ :** គណៈកម្មការនេះមានភារកិច្ចដូចខាងក្រោម :

- ទទួលខុសត្រូវតាមដាន ត្រួតពិនិត្យនូវរាល់សកម្មភាពវេចខ្ចប់ឡើងវិញ និងការដឹកជញ្ជូនសំណល់ ចេញពីព្រះរាជាណាចក្រកម្ពុជា របស់ភាគីកូមី ។
- ទទួលខុសត្រូវសំរបសំរួលរៀបចំសំណុំបែបបទ និងអាជ្ញាប័ណ្ណនាំចេញផ្តល់ ដល់ភាគីកូមី ។

**ប្រការ ៣ :** អភិបាលក្រុងព្រះសីហនុ ត្រូវសហការ និងសំរបសំរួលជាមួយគណៈកម្មការនេះបំពេញភារកិច្ចអោយបានល្អ និងប្រកបដោយសុវត្ថិភាព ។

**ប្រការ ៤ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន ក្រសួងពាណិជ្ជកម្ម ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អភិបាលក្រុងព្រះសីហនុ កំពង់ផែក្រុងព្រះសីហនុព្រមទាំង សាមីខ្លួន ដូចមានចែងក្នុងប្រការ ១ ខាងលើ ត្រូវអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ឧបនាយករដ្ឋមន្ត្រី
ហត្ថលេខា និងត្រា
**ស ខេង**

★★★

រាជធានីភ្នំពេញ,ថ្ងៃទី០៩ ខែមេសា ឆ្នាំ១៩៩៩

## សេចក្តីសំរេចលេខ ៣៤ សសរ
## ស្តីពីការបង្កើតគណៈកម្មាធិការពិនិត្យវាយតំលៃ សញ្ញាប័ត្រ និង លិខិតបញ្ជាក់ការសិក្សា

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើត ក្រសួងអប់រំ យុវជន និងកីឡា
- យោងសេចក្តីសំរេចលេខ ៦៣ សសរ ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតគណៈកម្មាធិការពិនិត្យវាយតម្លៃកិតសញ្ញាប័ត្រ និង លិខិតបញ្ជាក់ការសិក្សា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

**សំរេច**

**ប្រការ ១ :** បង្កើតគណៈកម្មាធិការចំរុះដែលមានឈ្មោះ " គណៈកម្មាធិការពិនិត្យវាយតម្លៃកិតសញ្ញាប័ត្រ និង លិខិតបញ្ជាក់ការសិក្សា " ដែលមានសមាសភាពដូចមានខាងក្រោម ៖

១- ឯកឧត្តម ថ្នាក់ដឹកនាំ ក្រសួងអប់រំ យុវជន និងកីឡា ទទួលបន្ទុកការងារឧត្តមសិក្សា ប្រធាន
២- ឯកឧត្តម អគ្គនាយកឧត្តមសិក្សាបច្ចេកទេស និងវិជ្ជាជីវៈ អនុប្រធាន
៣- ឯកឧត្តម អគ្គនាយក អប់រំ សមាជិក
៤- លោក តំណាងទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក
៥- លោក តំណាងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សមាជិក
៦- លោក តំណាងក្រសួងសុខាភិបាល សមាជិក
៧- លោក ប្រធាននាយកដ្ឋានឧត្តមសិក្សា សមាជិក
៨- លោក ប្រធាននាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ សមាជិក

**ប្រការ ២ :** គណៈកម្មាធិការនេះមានភារកិច្ច
- វាយតម្លៃកិតសញ្ញាប័ត្រ និងលិខិតបញ្ជាក់ការសិក្សាក្នុង និងក្រៅ ប្រទេស តាមសំណើសុំវាយតម្លៃពីបណ្តាស្ថាប័ននានាទូទាំងប្រទេស ។
- កសាងលក្ខណៈវិនិច្ឆ័យសំរាប់វាយតម្លៃកិតសញ្ញាប័ត្រ និងលិខិតបញ្ជាក់ការសិក្សា ក្នុង និង ក្រៅប្រទេស ។

**ប្រការ ៣ :** គណៈកម្មាធិការមានទីស្នាក់ការក្នុងក្រសួងអប់រំ យុវជន និងកីឡា និងមានសិទ្ធិប្រើប្រាស់ត្រា ក្រសួងអប់រំ យុវជន និងកីឡា ដើម្បីសំរួលការងារ ។

**ប្រការ ៤ :** សមាជិកគណៈកម្មាធិការ ត្រូវចូលរួមប្រជុំការងារតាមការអញ្ជើញរបស់ប្រធាន ។ ក្នុងពេលប្រជុំវាយតម្លៃកិតសញ្ញាប័ត្រ និងលិខិតបញ្ជាក់ការសិក្សា ក្រសួង ឬ ស្ថាប័នដែលមានការពាក់ព័ន្ធ អាចចាត់តំណាងមកជួយបំភ្លឺ និង ផ្តល់ព័ត៌មានដែលចាំបាច់បន្ថែម ជូនគណៈកម្មាធិការ ។

**ប្រការ ៥ :** គណៈកម្មាធិការ មានសិទ្ធិបង្កើតក្រុមជំនួយការមួយក្រុម ដើម្បីធ្វើជាសេនាធិការ ។

**ប្រការ ៦ :** សេចក្តីសំរេចលេខ ៦៣ សសរ ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ ១៩៩៥ របស់គណៈរដ្ឋមន្ត្រី និងបទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងបទបញ្ញត្តិនៃសេចក្តីសំរេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៧ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួងស្ថាប័នពាក់ព័ន្ធ និងឯកឧត្តម

អស់លោក ជាគណៈកម្មាធិការដូចក្នុងប្រការ ១ មានភារកិច្ច អនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែមេសា ឆ្នាំ១៩៩៩

## សេចក្តីសំរេចលេខ ៣៥ សសរ

## ស្តីពីការបង្កើតគណៈកម្មការរៀបចំពិធីសម្ពោធ និង ដាក់អោយដំណើរការជាផ្លូវការខេត្តឧត្តរមានជ័យ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០១៩៥/០៧ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតខេត្តឧត្តរមានជ័យ
- បានឃើញព្រះរាជក្រមលេខ នស/រកត/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

ប្រការ ១ : ត្រូវបានបង្កើតគណៈកម្មាធិការមួយមានឈ្មោះថា គណៈកម្មការរៀបចំពិធីសម្ពោធ និង ដាក់អោយដំណើរការជាផ្លូវការ ខេត្តឧត្តរមានជ័យ ដែលរួមមានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១-ឯកឧត្តម ប្រាំ សុខា | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ជាប្រធាន |
| ២-ឯកឧត្តម ចាយ សាំងយុន | រដ្ឋលេខាធិការក្រសួងការពារជាតិ | ជាអនុប្រធាន |
| ៣-ឯកឧត្តម ពេជ ម៉ុនធិន | រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ | ជាសមាជិក |
| ៤-លោក ម៉ុន សម | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជាសមាជិក |
| ៥-ឯកឧត្តម ប្រាជ្ញ ចន្ទ | អគ្គនាយករដ្ឋបាលក្រសួងមហាផ្ទៃ | ជាសមាជិក |
| ៦-ឯកឧត្តម តេខ សាខឿ | អគ្គនាយករង អគ្គនាយកដ្ឋាននគរបាលជាតិ | ជាសមាជិក |